ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃសុក្រ ៤ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមករា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការចូលជាធរមាន និងប្រសិទ្ធភាពអនុវត្តកិច្ចព្រមព្រៀង រវាងកម្ពុជា-សិង្ហបុរី និងកម្ពុជា-ថៃ ស្តីពីការចៀសវាង ការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា៖

- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (the Agreement between the Government of the Kingdom of Cambodia and the Government of the Republic of Singaporefor the Avoidance of Double Taxation and the Prevention of Fiscal Evasion with respect to Taxes on Income) ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ និង
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (the Agreement between the Government of the Kingdom of Cambodia and the Government of Kingdom of Thailand for the Avoidance of Double Taxation and the Prevention of Fiscal Evasion with respect to Taxes on Income) ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី០៧ ខែកញ្ញាឆ្នាំ២០១៧

ហើយត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០២២ ចុះថ្ងៃទី០៩ខែធ្នូឆ្នាំ២០១៧។ ដោយអនុលោមតាមមាត្រា ២៨ ស្តីពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងទាំងពីរ ភាគីទាំងពីរបានធ្វើការជូនដំណឹងជាផ្លូវការទៅវិញទៅមក ស្តីពីការបញ្ចប់សព្វគ្រប់ នូវនីតិវិធីផ្ទៃក្នុងរបស់ប្រទេសរៀងៗខ្លួន ដែលនាំឱ្យកិច្ចព្រមព្រៀងទាំងពីរចូលជាធរមានក្នុងឆ្នាំ២០១៧ និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិ មេត្តាជ្រាប និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈទូរស័ព្ទលេខ៖ ០១៧ ៤៦៥ ៧៣៨, ០១២ ៤៧៣ ៧២៧, ០១២ ៧៧៧ ៣៧៤ ឬចូលទៅកាន់គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ។